**របាយការណ៍**

**ស្តីពី**

**លទ្ធផលនៃការពិនិត្យការអនុវត្តចំណូលថវិកា ប្រចាំត្រីមាសទី១ ឆ្នាំ២០២១**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

## I-ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១

យោងតាមព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ បានប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។ នៅក្នុងច្បាប់នេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានគ្រោងចំណូលឆ្នាំ២០២១ សរុបមានចំនួន ៣៥ ៤២៥,៤ លានរៀល ក្នុងនោះ ៖

**(ក) រដ្ឋបាលកណ្តាល៖** បានគ្រោងចំណូលសរុបចំនួន ៣៥ ៤២៤ លានរៀល ចំណូលនេះរួមមាន :

(១)ផលទុននៃទ្រព្យសម្បត្តិរដ្ឋមានចំនួន២០ ៩៩២ លានរៀល ស្មើនឹង៧៥,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ (២)ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវាមានចំនួន ១១ ១៦២ លានរៀល ស្មើនឹង១០៣,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ (៣) ផលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម មានចំនួន៣ ២៧០ លានរៀល ស្មើនឹង១១៤,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ ។

**(ខ) មន្ទីររាជធានី ខេត្ត៖** បានគ្រោងចំណូលសរុបចំនួន១,៤ លានរៀល ស្មើនឹង ១០០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ចំណូលនេះបានពីការជួលដីទំនេរនៃផលទុនពីការលក់ជួលទ្រព្យសម្បត្តិនិងសេវារបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ។

## II-លទ្ធផលសម្រេចបាន

ដោយអនុវត្តតាមច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ នៅក្នុងត្រីមាសទី១ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុវត្តប្រមូលចំណូល សរុបមានចំនួន ៣០ ០៨០,៤ លានរៀល ស្មើនឹង៨៤,៩ % ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៣៤៩,៣,%ធៀបនឹងកម្មវិធីដែលបានដាក់ចេញក្នុងនោះ ៖

**(ក) រដ្ឋបាលកណ្តាល៖** អនុវត្តប្រមូលចំណូល សរុបមានចំនួន៣០ ០៨០,៤លានរៀល ស្មើនឹង៨៤,៩ % ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ឬស្មើនឹង៣៤៩,៣%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ចំណូលនេះរួមមាន (១)ផលទុននៃទ្រព្យសម្បត្តិរដ្ឋមានចំនួន៦ ៧០០,១ លានរៀល ស្មើនឹង៣១,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១៤៤,៩%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (២) ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវាមានចំនួន៦ ៤៦២ លានរៀល ស្មើនឹង៥៧,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង២១២,៩%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (៣) ផលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម មានចំនួន១ ១៧០,៩ លានរៀល ស្មើនឹង៣៥,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១២២,៩ % ធៀបនឹងកម្មវិធីដែលបានដាក់ចេញ(៤)ផលហិរញ្ញវត្ថុ មានចំនួន ២៥០,១លានរៀល ដែលជាចំណូលបានមកពីការបង់សំណោសចំណាយប្រាក់បៀវត្សនិង(៥) ផលពិសេសផ្សេងៗមានចំនួន ១៥ ៤៩៧,៣លានរៀល ដែលជាចំណូលមិនបានគ្រោងនៅក្នុងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ឡើយ ។

**(ខ) មន្ទីររាជធានី ខេត្ត ៖**

នៅក្នុងត្រីមាសទី១នេះមន្ទីរមិនទាន់បានអនុវត្តចំណូលពីថ្លៃឈ្នួលដីទេ។

ជារួមការអនុវត្តចំណូល របស់រដ្ឋបាលកណ្តាលសម្រេចបានខ្ពស់ ដោយសារមានចំណូលបន្ថែមពីការលក់ផ្តាច់ដី

សម្បទាន២កន្លែងនិងដីរបស់រដ្ឋបាលជលផល ។ ម្យ៉ាងទៀតដោយពិនិត្យទៅតាមប្រភេទចំណូលនីមួយៗឃើញថាមានភាពកើនខ្ពស់ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ជាក់ស្តែងដូចជា៖

(១) ផលទុននៃទ្រព្យសម្បត្តិរដ្ឋអនុវត្តបាន១៤៤,៩% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ករណីនេះបណ្តាលមកពីចំណូលពីចំណូលផលពីព្រៃឈើអនុវត្តបាន៦៥,៩%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៣០២,៧%ធៀបនឹងកម្មវិធីដែលបានដាក់ចេញនិងចំណូលពីសម្បទានដីសេដ្ឋកិច្ចអនុវត្តបាន៣,៩%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១៧,៤%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

(២)ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវា អនុវត្តបានខ្ពស់គឺដោយសារចំណូលពីការលក់ឯកសារ លតាប័ត្រនិងលិខិតបោះពុម្ពផ្សេងៗអនុវត្តបាន១៣៥,៧% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៨១៤%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ។ ចំណូលពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាលនិងការគ្រប់គ្រងរដ្ឋបាលផ្សេងៗអនុវត្តបានចំនួន ១៣៦,៤%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ។ ចំពោះការជួលទ្រព្យសម្បត្តិរដ្ឋដូចជាការជួលដីទំនេរ និងដីមានអគារអនុវត្តបាន១៥៣,៧%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ ដោយឡែកចំណូលផលពីការគ្រប់គ្រងរដ្ឋបាលដែលបានពីការត្រួតពិនិត្យអនាម័យសត្វនិងការត្រួតពិនិត្យគុណភាពផលិតផល អនុវត្តបាន៦៤,១%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង២៣០,៧%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

(៣) ចំណូលពីការផាកពិន័យនិងដាក់ទណ្ឌកម្មអនុវត្តបាន៣៥,៨%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១២២,៩%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ លទ្ធផលនេះបានមកដោយសារការផាកពិន័យលើផលិតផលសាច់សត្វ និងការដឹកជញ្ជូនសត្វរបស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ អនុវត្តបាន១២០ % នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៤៨០%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ការពិន័យលើការទិញ-លក់ជីនិងថ្នាំកសិកម្មខុសច្បាប់ អនុវត្តបាន៣៩,៤% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១៦១,៤%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ការពិន័យលើការនេសាទខុសច្បាប់ អនុវត្តបាន១១៤,៧%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៤៥៨,៩%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ និងការពិន័យលើបទល្មើសព្រៃឈើ អនុវត្តបាន១៣,៤ %នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៩៧,៤%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ។

## III-ទិសដៅអនុវត្តបន្ត

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្តខិតខំនិងជំរុញការប្រមូលចំណូលបង់ចូលថវិកាជាតិស្របទៅតាមកម្មវិធីចំណូលប្រចាំត្រីមាសទី២ឆ្នាំ២០២១ ដែលមានទឹកប្រាក់សរុបចំនួន៨ ៦៥៦,១លានរៀល។ កិច្ចការបន្ទាន់មួយទៀតដែលក្រសួងត្រូវអនុវត្ត គឺបន្តរៀបចំឯកសារកែសម្រួលកម្រងសេវាសាធារណៈនិងសេចក្តីព្រាងប្រកាសអន្តរក្រសួងដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## IV-សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមកការអនុវត្តប្រមូលចំណូលប្រចាំត្រីមាសទី១ របស់រដ្ឋបាលកណ្តាលសម្រេចបានលទ្ធផលល្អប្រសើរគឺលើសផែនការធៀបនឹងកម្មវិធីដែលបានដាក់ចេញទាំងផ្នែកចំណូលពីសេវាសាធារណៈ និងការជួលដីធ្លី អគារ គួបផ្សំនឹងចំណូលពីការលក់ផ្តាច់ទីតាំងដីសម្បទានសេដ្ឋកិច្ចពីរកន្លែង និងទីតាំងដីរបស់រដ្ឋបាលជលផលដែលមិនបានគ្រោងនៅក្នុងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ។

ដោយឡែក មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺនៅមិនទាន់បានអនុវត្តប្រមូលចំណូលពីថ្លៃឈ្នួលដីទំនេរនៅឡើយ។

ដូច្នេះដើម្បីអនុវត្តប្រមូលចំណូលឲ្យបានតាមផែនការឆ្នាំ២០២១ អង្គភាពពាក់ព័ន្ធទទួលបន្ទុកប្រមូលចំណូលត្រូវបន្តការយកចិត្តទុកដាក់ក្នុងការប្រមូល និងបង់ចំណូលឲ្យបានទាន់ពេលវេលា គួបផ្សំនឹងការប្រតិបត្តិតាមនីតិវិធីថ្មីៗពាក់ព័ន្ធការបង់ចំណូលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ថ្ងៃអង្គារ៩កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១

**រដ្ឋលេខាធិការនិងជាអនុប្រធានក្រុមការងាររៀបចំថវិកា**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

# របាយការណ៍
# ស្តីពី
# លទ្ធផលនៃការពិនិត្យការអនុវត្តចំណាយថវិកាប្រចាំត្រីមាសទី១ ឆ្នាំ២០២១
# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សេចក្តីផ្តើម**:

ឆ្នាំ២០២១ គឺជាឆ្នាំទី៦ ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តថវិកាកម្មវិធីពេញលេញដោយឈរលើគោលបំណងគោលនយោបាយរួមមួយគឺ "ជំរុញកំណើនកសិកម្មប្រកបដោយការប្រកួតប្រជែង ផលិតផលមានគុណភាព សុវត្ថិភាព និងអាហារូបត្ថម្ភព្រមទាំងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានដី ព្រៃឈើ និងជលផលប្រកបដោយចិរភាព"។ ដើម្បីឈានទៅសម្រេចគោលបំណងនេះ ក្រសួងបានដាក់ចេញនូវយុទ្ធសាស្ត្រសម្រាប់អនុវត្តជាកម្មវិធី អនុកម្មវិធីនិងចង្កោមសកម្មភាពទៅតាមផ្នែកជំនាញនៃអង្គភាពថវិកាទាំង៤៦អង្គភាព ក្នុងនោះថ្នាក់កណ្តាលមានចំនួន២១អង្គភាពថវិកានិងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន២៥ រាជធានីខេត្ត។

## I-ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១

យោងតាមព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ បានប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។ នៅក្នុងច្បាប់នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានគ្រោងឥណទានចំណាយថវិកា ឆ្នាំ២០២១ សរុបមានចំនួន ២៧៧ ៥៥៣ លានរៀល ក្នុងនោះ ៖

**(ក) រដ្ឋបាលកណ្តាល**៖ បានគ្រោងឥណទានចំណាយថវិកាសរុបចំនួន ១៨០ ២៧៧ លានរៀល រួមមាន៖

- ឥណទានចំណាយថវិកាចរន្ត មានចំនួន ១៦៤ ២៧៧ លានរៀល
- ឥណទានចំណាយថវិកាមូលធន មានចំនួន ១៦ ០០០ លានរៀល

**(ខ) មន្ទីររាជធានី ខេត្ត** ៖បានគ្រោងឥណទានចំណាយថវិកាចរន្តសរុបចំនួន ៩៧ ២៧៦ លានរៀល

## II-លទ្ធផលសម្រេចបាន

ដោយអនុវត្តតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ នៅក្នុងត្រីមាសទី១ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ អនុវត្តចំណាយ តាមអាណត្តិបើកប្រាក់សរុបចំនួន៤៩ ០៤៧,៤ លានរៀល ស្មើនឹង១៧,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ក្នុងនោះរដ្ឋបាលកណ្តាលអនុវត្តបានចំនួន៣១ ៤២៨,៦លានរៀលស្មើនឹង១៧,៤%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៩១,៣% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ។ រីឯមន្ទីររាជធានី ខេត្តអនុវត្តបានចំនួន១៧ ៦១៨,៨លានរៀល ស្មើនឹង ១៨,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ឬស្មើនឹង៨៤,៦% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

**(ក) រដ្ឋបាលកណ្តាល៖**

ដោយពិនិត្យទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាឃើញថា ការអនុវត្តចំណាយតាមអាណត្តិបើកប្រាក់របស់រដ្ឋបាលកណ្តាល (២១អង្គភាពថវិកា) សម្រេចបានចំនួន៣១ ៤២៨,៦ លានរៀល ដោយក្នុងនោះ (ក)ការទិញ(ជំពូក៦០) អនុវត្តបានចំនួន៨៥២,៥ លានរៀល ស្មើនឹង៣,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង២៨,៤% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ខ)សេវាកម្ម (ជំពូក៦១) អនុវត្តបានចំនួន៣៥៦,៧លានរៀលស្មើនឹង០,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ឬស្មើនឹង៦,៥% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (គ)បន្ទុកបុគ្គលិក(ជំពូក៦៤ ) អនុវត្តបានចំនួន២៣ ៣៧៦,៥ លានរៀល ស្មើនឹង៣២,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១១៥,២% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ឃ) ឧបត្ថម្ភធន (ជំពូក៦៥) អនុវត្តបានចំនួន៦ ៨៤២,៩លានរៀល ស្មើនឹង៣០,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង ១២១,៧% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

ម្យ៉ាងវិញទៀត ដោយពិនិត្យលើចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិការបស់អង្គភាពរដ្ឋបាលកណ្តាល ឃើញថាទឹកប្រាក់សរុបចំនួន៣១ ៤២៨,៦ លានរៀល នេះត្រូវបានអនុវត្តចំណាយសម្រាប់៖

(១) បង្កើនផលិតភាព និងពិពិធកម្មកសិកម្ម និងកសិធុរកិច្ច (កម្មវិធីទី១) ចំនួន១ ៨៤០,៩ លានរៀល ស្មើនឹង៦,៧%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១

(២) ជំរុញផលិតកម្មសត្វ និងសុខភាពសត្វ ( កម្មវិធីទី២) ចំនួន១០១,៨ លានរៀល ស្មើនឹង០,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១

(៣) គ្រប់គ្រងធនធានជលផលនិងអភិវឌ្ឍវារីវប្បកម្ម (កម្មវិធីទី៣) ចំនួន៥២៩,២ លានរៀល ស្មើនឹង៣,៨%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១

(៤) គ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើនិងសត្វព្រៃ (កម្មវិធីទី៤) ចំនួន ៤៩៣,៣លានរៀល ស្មើនឹង៤,៨ % ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១

(៥) បង្កើនប្រសិទ្ធភាពសេវាគាំទ្រនិងអភិវឌ្ឍន៍ធនធានមនុស្ស(កម្មវិធីទី៥) ចំនួន២៨ ៤៦៣,៣ លានរៀលស្មើនឹង២៨,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ។

**(ខ) មន្ទីររាជធានី ខេត្ត ៖**

ផ្អែកតាមការពិនិត្យការអនុវត្តចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ឃើញថាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទទាំង២៥រាជធានី ខេត្ត បានអនុវត្តចំណាយថវិកាតាមអាណត្តិបើកប្រាក់សរុបមានចំនួន ១៧ ៦១៨,៨ លានរៀល គឺអនុវត្តបានទាបជាងឆ្នាំ២០២០ក្នុងរយៈពេលដូចគ្នា ប្រមាណជា១៦,៥% ក្នុងនោះចំណាយលើ (ក)ការទិញ (ជំពូក៦០) អនុវត្តបានចំនួន១ ៣២៩,៣ លានរៀល ស្មើនឹង១១,៨ % ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ឬស្មើនឹង៦៧,៨% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ខ)សេវាកម្ម (ជំពូក៦១) អនុវត្តបានចំនួន១ ៩០៧,៧ លានរៀលស្មើនឹង៨,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ឬស្មើនឹង៤២,៨% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (គ) បន្ទុកបុគ្គលិក (ជំពូក៦៤ ) អនុវត្តបានចំនួន១៣ ១៣៣,៧ លានរៀល ស្មើនឹង២៣,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១០០,១% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ឃ) អត្ថប្រយោជន៍សង្គម (ជំពូក៦២) អនុវត្តបានចំនួន១ ២៤៨,២ លានរៀល ស្មើនឹង១៧,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៩៦,៨% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ង) ជំពូក៦៣ (ពន្ធនិងអាករ) មិនទាន់បានអនុវត្តនៅឡើយនៅក្នុងត្រីមាសទី១នេះ។

ម្យ៉ាងទៀតពិនិត្យទៅតាមចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិកា តួលេខអនុវត្តចំណាយថវិកាសរុប ចំនួន ១៧ ៦១៨,៨ លានរៀល ត្រូវបានអនុវត្តដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តដូចខាងក្រោម៖

ឯកតា: រៀល

| មន្ទីររាជធានី ខេត្ត | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ | ការអនុវត្តត្រីមាសទី១ | %ធៀបច្បាប់ហិរញ្ញវត្ថុ ២០២១ | %ធៀបកម្មវិធីត្រីមាសទី១ |
|---|---|---|---|---|
| បន្ទាយមានជ័យ | 3 711 100 000 | 543 301 439 | 14.6% | 38.2% |
| បាត់ដំបង | 6 489 100 000 | 1 786 658 740 | 27.5% | 138.2% |
| កំពង់ចាម | 3 949 300 000 | 1 043 244 948 | 26.4% | 114.4% |
| កំពង់ឆ្នាំង | 3 878 800 000 | 834 428 100 | 21.5% | 112.5% |
| កំពង់ស្ពឺ | 4 923 900 000 | 1 372 683 600 | 27.9% | 149.3% |
| កំពង់ធំ | 5 497 900 000 | 1 106 888 676 | 20.1% | 81.5% |
| កំពត | 3 999 000 000 | 592 854 450 | 14.8% | 65.2% |
| កណ្តាល | 6 180 000 000 | 1 495 551 427 | 24.2% | 91.7% |
| កោះកុង | 2 498 100 000 | 331 615 000 | 13.3% | 58.6% |

| | | | | |
|---|---|---|---|---|
| ក្រចេះ | 3 903 800 000 | 358 744 000 | 9.1% | 36.3% |
| មណ្ឌលគិរី | 2 898 400 000 | 300 872 580 | 10.4% | 59.8% |
| រាជធានីភ្នំពេញ | 4 333 100 000 | 824 916 933 | 19% | 83.9% |
| ព្រះវិហារ | 2 924 700 000 | 428 751 000 | 14.7% | 66.2% |
| ព្រៃវែង | 4 515 000 000 | 566 879 065 | 12.6% | 69.2% |
| ពោធិ៍សាត់ | 3 875 200 000 | 780 009 900 | 20.1% | 72.4% |
| រតនគិរី | 3 080 700 000 | 381 110 731 | 12.4% | 73.6% |
| សៀមរាប | 5 712 400 000 | 850 277 750 | 14.9% | 65.5% |
| ព្រះសីហនុ | 2 887 000 000 | 351 252 693 | 12.2% | 53.9% |
| ស្ទឹងត្រែង | 3 270 000 000 | | | |
| ស្វាយរៀង | 2 894 700 000 | 384 549 700 | 13.3% | 207% |
| តាកែវ | 5 153 600 000 | 1 217 213 698 | 23.6% | 94.5% |
| ឧត្តរមានជ័យ | 3 007 100 000 | 991 345 000 | 32.9% | 92.8% |
| កែប | 1 717 500 000 | 222 855 000 | 12.9% | 52.1% |
| ប៉ៃលិន | 2 285 800 000 | 363 135 490 | 15.9% | 81.1% |
| ត្បូងឃ្មុំ | 3 689 800 000 | 489 613 714 | 13.3% | 65.6% |

## III-**បញ្ហាប្រឈម**

យោងតាមការអធិប្បាយខាងលើឃើញថា ការអនុវត្តចំណាយថវិកាប្រចាំត្រីមាសទី១ឆ្នាំ២០២១ សម្រេចបានទាបជាងឆ្នាំ២០២០ ដោយសារក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានកែសម្រួលនីតិវិធីមួយចំនួន ដើម្បីឆ្លើយតបនឹងការផ្ទុះជម្ងឺឆ្លងធ្ងន់ធ្ងរកូវីដ-១៩ តាមរយៈការចេញនូវប្រកាសណែនាំស្តីពីនីតិវិធីថ្មីៗពាក់ព័ន្ធការចំណាយរដ្ឋទេយ្យបុរេប្រទាន ការចំណាយប្រាក់បេសកកម្មក្នុងនិងក្រៅប្រទេស ការចំណាយរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា សន្និសិទ និងកិច្ចប្រជុំផ្សេងៗ ។ ការងារនេះតម្រូវឲ្យអង្គភាពថវិកានីមួយៗសិក្សាស្វែងយល់ឲ្យបានច្បាស់លាស់ និងត្រូវរៀបចំឯកសារពាក់ព័ន្ធមួយចំនួនទំរាំអាចអនុវត្តការចំណាយបាន។

ទន្ទឹមនេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជួបបញ្ហាប្រឈមមួយចំនួនដែលធ្វើឲ្យដំណើរការចំណាយមានការយឺតយ៉ាវខ្លះៗ ទាំងចំណាយចរន្តនិងចំណាយមូលធនដែលបញ្ហាលំបាកទាំងនោះមានដូចជា៖

-ការផ្តល់ធានាចំណាយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភាពយឺតយ៉ាវដែលនាំឲ្យរាំងស្ទះដល់ការងារអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ(ទាំងថវិកាចរន្តនិងមូលធន)។

-ឯកសារគាំទ្រសម្រាប់ជម្រះទូទាត់រដ្ឋទេយ្យបុរេប្រទានរបស់អង្គភាពថវិកាមួយចំនួន មិនទាន់បំពេញបានគ្រប់គ្រាន់និងទាន់ពេលវេលា។

## IV-**ទិសដៅអនុវត្តបន្ត**

អង្គភាពថវិកានៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវខិតខំអនុវត្តចំណាយថវិកាក្នុងការធ្វើសកម្មភាពការងារដើម្បីសម្រេចបានសូចនាកររបស់ខ្លួនទៅតាមកម្មវិធីចំណាយប្រចាំត្រីមាសទី២ឆ្នាំ២០២១ ដែលមានទឹកប្រាក់សរុបចំនួន៧០ ៤៩៨ ៥៣៨ ០០០ រៀល ក្នុងនោះរួមមាន ៖

ឯកតា: រៀល

| ចំណាត់ថ្នាក់សេដ្ឋកិច្ច | រដ្ឋបាលកណ្តាល | មន្ទីររាជធានី ខេត្ត |
|---|---|---|
| ជំពូក ៦០ (ការទិញ) | 4 657 700 000 | 7 084 254 000 |
| ជំពូក ៦១ (សេវាកម្ម) | 2 100 000 000 | 9 221 662 000 |
| ជំពូក ៦៤ (បន្ទុកបុគ្គលិក) | 21 620 000 000 | 14 814 482 000 |
| ជំពូក៦២(អត្ថប្រយោជន៍សង្គម) | 0 | 5 320 640 000 |
| ជំពូក ៦៥ (ឧបត្ថម្ភធន) | 5 622 000 000 | 0 |
| ជំពូក ៦៣ (ពន្ធនិងអាករ) | 50 000 000 | 7 800 000 |
| **សរុប** | **34 049 700 000** | **36 448 838 000** |

V-**សេចក្តីសន្និដ្ឋាន**

ឆ្លងតាមការពិនិត្យវាយតម្លៃការអនុវត្តចំណាយថវិកា ប្រចាំត្រីមាសទី១ របស់អង្គភាពនៃរដ្ឋបាលកណ្តាល ជារួមសម្រេចបាន៩១,៣% នៃកម្មវិធីដែលបានដាក់ចេញ លទ្ធផលនេះបានមកដោយសារការអនុវត្តចំណាយបន្ទុកបុគ្គលិក(ជំពូក៦៤) និងចំណាយឧបត្ថម្ភធន(ជំពូក៦៥)អនុវត្តលើសកម្មវិធីត្រីមាសទី១ប្រមាណជា២០% រីឯការចំណាយលើការទិញ(ជំពូក៦០)អនុវត្តបានទាបជាងកម្មវិធីប្រមាណជា៧០% និងចំណាយសេវាកម្ម(ជំពូក៦១) អនុវត្តបានទាបជាងកម្មវិធីប្រមាណជា៩៣% ទាំងនេះគឺដោយសារ(១)ដំណើរការទូទាត់ចំណាយតាមនីតិវិធីលទ្ធកម្ម ក្នុងកំឡុងពេលនេះមិនទាន់ដល់ពេល (២) ការទូទាត់ចំណាយបុរេប្រទាន និងរជ្ជទេយ្យបុរេប្រទានមានតិចតួចបំផុតដោយសារមានការកែសម្រួលនីតិវិធីអនុវត្ត ទន្ទឹមនេះការទូទាត់ចំណាយជំពូក២១ និងចំណាយបង់ពន្ធរថយន្ត (ជំពូក៦៣) មិនទាន់បានអនុវត្តនៅឡើយ។

ចំពោះការអនុវត្តចំណាយថវិការបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជារួមសម្រេចបានល្អបង្គួរ ក្នុងកម្រិត ៨៤,៦%នៃកម្មវិធីដែលបានដាក់ចេញ។ ទោះបីជាយ៉ាងនេះក្តីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ចំនួនប្រាំគឺខេត្តបន្ទាយមានជ័យ ក្រចេះ មណ្ឌលគិរី ព្រះសីហនុ និងខេត្តកែបអនុវត្តចំណាយថវិកាបានទាប ដែលត្រូវធ្វើការជំរុញនិងកែលម្អបន្ថែមទៀត។ដោយឡែកមន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទខេត្តស្ទឹងត្រែង ពុំបានផ្តល់របាយការណ៍មកក្រសួងនៅឡើយ។

សរុបសេចក្តីមក ការអនុវត្តចំណាយថវិកា តាមអាណត្តិបើកប្រាក់ប្រចាំត្រីមាសទី១ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជារួមនៅតែទទួលបានលទ្ធផលល្អ ទោះបីជាមានការកែសម្រួលនីតិវិធីមួយចំនួននិងធ្វើឲ្យការអនុវត្តចំណាយលើការទិញនិងចំណាយសេវាកម្មអនុវត្តបានទាបក្តី ។ ម្យ៉ាងទៀតចំណាយប្រភេទនេះនឹងកើនឡើងក្នុងត្រីមាសបន្ទាប់ប្រសិនបើស្ថានភាពនៃការឆ្លងជម្ងឺកូវីដ-១៩ បានធូរស្រាលគួបផ្សំនឹងបែបបទ នីតិវិធីពាក់ព័ន្ធចំណាយត្រូវបានរៀបចំបំពេញរួចរាល់។

ថ្ងៃអង្គារ ៩កើត ខែពិសាខ ឆ្នាំ ជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១

**រដ្ឋលេខាធិការនិងជាអនុប្រធានក្រុមការងាររៀបចំថវិកា**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**